ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច ការងារ

បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

លេខ ២៦១ សកបយ ភ្នំពេញ, ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០០១

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ហត្ថពលកម្មបរទេស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស.រកត-១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស.រកម-០៣៩៧-០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

## សំរេច

ប្រការ ១ : ម្ចាស់ឬនាយកសហគ្រាសគ្រឹះស្ថានទាំងឡាយ ដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ នៅពេលដែលត្រូវការជ្រើសរើសកម្មករនិយោជិត ត្រូវធ្វើការជ្រើសរើសជនជាតិខ្មែរជាអាទិភាព ។

ក្នុងករណីដែលមិនអាចរកបាននូវជនជាតិខ្មែរ ដើម្បីបំពេញតាមសេចក្តីត្រូវការចាំបាច់ណាមួយ ម្ចាស់ឬនាយកសហគ្រាសគ្រឹះស្ថានអាចធ្វើការជ្រើសរើសហត្ថពលកម្មបរទេស ដែលជាអ្នកឯកទេស អ្នកបច្ចេកទេស ឬអ្នកមានជំនាញវិជ្ជាជីវៈ សម្រាប់ចូលបំរើការងារនៅកន្លែងដែលរកហត្ថពលកម្មខ្មែរមិនបាននោះ ដោយត្រូវធ្វើសំណើជាលាយលក្ខអក្សរស្នើសុំការអនុញ្ញាតិជាមុន មកក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

សំណើស្តីពីសេចក្តីត្រូវការហត្ថពលកម្មបរទេសសម្រាប់ឆ្នាំបន្ត ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ដាច់ពីគ្នានូវចំនួនកម្មករនិយោជិតខ្មែរ និងបរទេសដែលមានបច្ចុប្បន្ន និងមូលហេតុចំបងដែលនាំឱ្យមានសេចក្តីត្រូវការហត្ថពលកម្មបរទេសនោះ ហើយត្រូវផ្ញើរមក ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ឱ្យបានមុនដំណាច់ខែវិច្ឆិកា នៃឆ្នាំនីមួយៗ ។

ប្រការ ២ : ផ្អែកតាមសំណើរបស់ម្ចាស់ ឬនាយក សហគ្រាស គ្រឹះស្ថាននីមួយៗ ជាទូទៅ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងអនុញ្ញាតិឱ្យប្រើប្រាស់ហត្ថពលកម្មបរទេសមិនលើសពី១០ភាគរយ នៃចំនួនកម្មករនិយោជិតខ្មែរសរុបទេ ។ អត្រាកំណត់អតិបរមា ១០ ភាគរយនេះ បែងចែកទៅតាមប្រភេទ នៃកម្មករនិយោជិត ដូចខាងក្រោមៈ

-និយោជិតការិយាល័យ ៣ ភាគរយ

-និយោជិត ឬកម្មករឯកទេស ៦ ភាគរយ

-និយោជិត ឬកម្មករគ្មានឯកទេស ១ ភាគរយ

ក្នុងករណីដែលសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសលើសពីអត្រា១០ភាគរយ សំណើសុំការអនុញ្ញាតិនេះត្រូវបញ្ជាក់ឱ្យបានលំអិត និងច្បាស់លាស់ អំពីមុខងារ មុខវិជ្ជាឯកទេស បច្ចេកទេស ឬមុខជំនាញវិជ្ជាជីវៈនៃជនបរទេសម្នាក់ៗ ដែលត្រូវធ្វើការជ្រើសរើសចូលបំរើការងារ និងមូលហេតុជាក់ស្តែងដែលនាំឱ្យមានសេចក្តីត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេសម្នាក់ៗ ដែលលើសអត្រា ១០ ភាគរយនោះផង ។

ប្រការ ៣: ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់ជនបរទេស ត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងជាលាយលក្ខអក្សរ ស្តីពីកិច្ចសន្យាការងាររបស់ជនបរទេសទាំងនោះមក នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នៃ

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចំពោះអ្នកនៅរាជធានីភ្នំពេញ និង មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុងនីមួយៗ ចំពោះអ្នកនៅខេត្តក្រុង ។

ប្រការ ៤: អ្នកប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិទាំងឡាយនៃប្រកាសនេះ នឹងត្រូវពិន័យ ឬទទួលទោសដូចមានចែងក្នុងជំពូក១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ៥ : ប្រកាសលេខ ១៨៥ សកអ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៧ ស្តីពីការប្រើប្រាស់ហត្ថពលកម្មបរទេស របស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

អ៊ិត សំហេង

ចម្លងជូន :

-ខុទ្ទកាល័យព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីជូនជ្រាប"
-អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្តក្រុង
-សមាគមនិយោជក
  "ដើម្បីអនុវត្ត"
-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍
  "ដើម្បីជួយផ្សព្វផ្សាយ"
-កាលប្បវត្តិ-ឯកសារ

.........ក្បាលលិខិតរបស់សហគ្រាស គ្រឹះស្ថាន........

..................................................................................................................................

នាយកសហគ្រាស គ្រឹះស្ថាន....................................

គោរពជូន

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

**កម្មវត្ថុ :** សំណើសុំកូតា ( quota ) ប្រើប្រាស់ហត្ថពលកម្មបរទេសសម្រាប់ឆ្នាំ .............

ចំពោះសេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរព និងជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីថា នៅក្នុងឆ្នាំ...............ខាងមុខនេះ .............................................................................................. នឹងត្រូវការប្រើប្រាស់ហត្ថពលកម្ម បរទេសជាសរុបចំនួន............. នាក់ ដោយមូលហេតុមិនអាចរកបាននូវហត្ថពលកម្មក្នុងស្រុក ដែលអាចទទួលរ៉ាប់រងអនុវត្តភារកិច្ចមួយចំនួនដោយប្រសិទ្ធិភាព បាននៅឡើយ ។

ចំពោះហត្ថពលកម្មបរទេស ដែលនឹងត្រូវការចំនួន..............នាក់នេះ គឺមានចំនួន.............នាក់ ដែលបាននឹងកំពុងធ្វើការនៅក្នុងសហគ្រាសរបស់យើងខ្ញុំក្នុងឆ្នាំ ......... នេះ ។ នៅក្នុងចំនួន .......... នាក់ដែលបាន និងកំពុងធ្វើការនោះ មានអ្នកដែលមកពីសាធារណរដ្ឋប្រជាមានិតចិនចំនួន ............ នាក់ ។ ដូច្នេះ យើងខ្ញុំសូមស្នើសុំបន្ថែមចំនួន ........... នាក់ទៀត ដែលក្នុងនោះមានអ្នកមកពីសាធារណរដ្ឋប្រជាមានិតចិន ចំនួន ........... នាក់ ផងដែរ ។ ( សូមមេត្តាពិនិត្យ តារាងស្នើសុំប្រើប្រាស់ហត្ថពលកម្មបរទេស ជូនជាប់មកជាមួយ )

អាស្រ័យហេតុដូចបានជំរាបជូនខាងលើនេះ យើងខ្ញុំសូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាពិនិត្យ និងសំរេចផ្តល់កូតា ( quota ) ប្រើប្រាស់ហត្ថពលកម្មបរទេសចំនួន ..............នាក់ សម្រាប់ឆ្នាំ ...............ដល់ ........... ........................................................................... ដោយអនុគ្រោះ ។

សូមឯកឧត្តមរដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

ភ្នំពេញ. ថ្ងៃទី .........ខែ ............ឆ្នាំ .........

នាយក.......................

.........ក្បាលលិខិតរបស់សហគ្រាស គ្រឹះស្ថាន........

..........................................................................................................................................

## តារាងស្នើសុំកូតា(quota)ប្រើប្រាស់ពលកម្មបរទេស

## សម្រាប់ឆ្នាំ...................

| លរ | ផ្នែកការងារ និងភារកិច្ចដែលត្រូវការហត្ថពលកម្មបរទេស | ចំនួនកម្មករនិយោជិតខ្មែរ | | ហត្ថពលកម្មបរទេស មានបច្ចុប្បន្ន | | ហត្ថពលកម្មបរទេស ដែលត្រូវការ | | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| | | បច្ចុប្បន្ន | ត្រូវការ | ចិន | សរុប | ចិន | សរុប | |
| | ក-រដ្ឋបាលគ្រប់គ្រង | | | | | | | |
| ១ | នាយក-នាយករង | ១ | ១ | ០ | ២ | ១ | ២ | |
| ២ | រដ្ឋបាល-គណនេយ្យ | ២០ | ២២ | ១ | ២ | ២ | ២ | |
| ៣ | .................. | ..... | ...... | ...... | ....... | ..... | ...... | |
| | ខ-ផ្នែក........... | | | | | | | |
| ៤ | ..................... | ..... | ...... | ...... | ....... | ..... | ....... | |
| ៥ | | | | | | | | |
| ៦ | | | | | | | | |
| | គ-ផ្នែក........... | | | | | | | |
| ៧ | ..................... | ..... | ...... | ...... | ........ | ..... | .......... | |
| ....... | | | | | | | | |
| ....... | | | | | | | | |
| ...... | | | | | | | | |
| | សរុប | | | | | | | |

ភ្នំពេញ. ថ្ងៃទី....... ខែ............ឆ្នាំ..........

នាយក.........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឈ្មោះសហគ្រាស.................................................................
អស័យដ្ឋាន.......................................................................
.........................................................................................

# សេចក្តីប្រកាសជូនដំណឹងអំពីកិច្ចសន្យាការងារ

ជនបរទេសចំនួន............នាក់

(D:)statistic Book1

| ល.រ | ឈ្មោះជនបរទេស | | ភេទ | សញ្ជាតិ | លេខលិខិតឆ្លងដែន | ពត៌មានក្នុងកិច្ចសន្យាការងារ | | | |
|---|---|---|---|---|---|---|---|---|---|
| | អក្សរខ្មែរ | អក្សរឡាតាំង | | | | ថ្ងៃចាប់ផ្តើម | ថ្ងៃបញ្ចប់ | មុខងារ | ប្រាក់ឈ្នួល |
| A | B | C | D | E | F | G | H | I | J |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |

បានបញ្ឈប់បញ្ជីនេះត្រឹមលេខរៀងទី...............(..............................) ។

.........................ថ្ងៃទី............ខែ............ឆ្នាំ..............

និយោជក